**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខៈ ៤៥ អយក.សជណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការអនុញ្ញាតឱ្យបើកដំណើរការសកម្មភាព និងសេវាកម្មនានា ដើម្បីគាំទ្រដល់ដំណើរការរៀននិងបង្រៀនជាលក្ខណៈបណ្តុំ នៅតាមគ្រឹះស្ថានសិក្សាឯកជន

ក្នុងដំណាក់កាលនៃការបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយជំងឺកូវីដ-១៩ "តាមគន្លងប្រក្រតីភាពថ្មី" ក្រសួងអប់រំ យុវជន និងកីឡាបានអនុញ្ញាតឱ្យចាប់ផ្តើមដំណើរការរៀន និងបង្រៀនជាលក្ខណៈបណ្តុំ សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ និងការបើកដំណើរការឡើងវិញនៃគ្រឹះស្ថានឧត្តមសិក្សា។ ដើម្បីគាំទ្រដល់ដំណាក់កាលនេះ និងយោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងអប់រំ យុវជន និងកីឡាសម្រេចអនុញ្ញាតឱ្យបើកដំណើរការសកម្មភាព និងសេវាកម្មនានា ដើម្បីគាំទ្រដល់ដំណើរការរៀននិងបង្រៀនជាលក្ខណៈបណ្តុំ នៅតាមគ្រឹះស្ថានសិក្សាឯកជន ដូចខាងក្រោម ៖

១. សកម្មភាពកីឡា ដែលមានការប៉ះទង្គិច ឬការប៉ះពាល់រាងរូបរាងកាយតិចតួច រួមមាន លំហាត់ប្រាណ អត្តពលកម្ម ការហែលទឹក កីឡាវាយសី

២. អាហារដ្ឋាន និងសេវាផ្តល់អាហារ ដែលអាចគ្រប់គ្រងពេលវេលាចូលទទួលទានអាហាររបស់សិស្សមិនឱ្យកុះករ និងរក្សាគម្លាតសុវត្ថិភាព (ប៉ុន្តែការផ្តល់ទឹកស្អាតពីប្រភពរួមគ្នា សម្រាប់ទទួលទាន ត្រូវបន្តផ្អាក)

៣. បណ្ណាល័យ បន្ទប់នេត្រា-សោតទស្សន៍ បន្ទប់ពិសោធន៍ ដែលពុំប្រើប្រាស់ប្រព័ន្ធត្រជាក់ ឬប្រព័ន្ធបន្សុទ្ធខ្យល់រួមគ្នា (ដោយត្រូវបើកបង្អួចឱ្យបានទូលាយ)

៤. សកម្មភាពសិល្បៈ ការរាំ ការប្រគុំតន្ត្រី ការសម្តែងកាយវិការ ដែលមានការប៉ះពាល់រាងរូបរាងកាយតិចតួច (ដោយមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះការធ្វើអនាម័យលើឧបករណ៍ ដែលត្រូវប្រើប្រាស់រួមគ្នា)

៥. សេវាដឹកជញ្ជូនសិស្ស ដោយបន្តរក្សាគម្លាតសុវត្ថិភាព (មិនអនុញ្ញាតឱ្យអង្គុយជាប់គ្នា)

ការបើកដំណើរការសកម្មភាព និងសេវាកម្មនានា ដើម្បីគាំទ្រដល់ដំណើរការរៀននិងបង្រៀនជាលក្ខណៈបណ្តុំ ដូចរៀបរាប់ខាងលើ នឹងត្រូវអនុវត្តស្របតាម "គោលការណ៍ប្រតិបត្តិស្តង់ដា (SOP)ស្តីពីសេវា

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

រថយន្តដឹកសិស្ស សេវាបណ្ណាល័យ សកម្មភាពអប់រំកាយនិងកីឡា សកម្មភាពសិល្បៈ និងសេវាអាហារដ្ឋាន នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ក្នុងបរិបទជំងឺកូវីដ-១៩ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១" និងគោលការណ៍ណែនាំដទៃទៀត ដែលមានជាធរមាន។

គ្រឹះស្ថានសិក្សាឯកជន ដែលមានបំណងបើកដំណើរការសកម្មភាព និងសេវាកម្មខាងលើ ត្រូវឆ្លងកាត់ការពិភាក្សាជាមួយមាតាបិតា និងអ្នកអាណាព្យាបាលសិស្សជាមុន។

ទទួលបានសេចក្តីជូនដំណឹងនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាឯកជន បុគ្គលិកអប់រំ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ១៣ រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ អគ្គនាយកដ្ឋានអប់រំ